ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការត្រួតពិនិត្យជម្ងឺប៉េស្តជ្រូក




រៀបចំដោយ៖ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ៖ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល



ឧបត្ថម្ភដោយ៖ គំរោងការផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ លោក ម៉ារី ម៉ាឃ្លីន** (Murray Maclean)

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាង គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និងផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់ លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រទូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា"។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័តិមានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈ ដូចខាងក្រោមនេះ ៖-

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័តិមានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័តិមានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័តិមានសំខាន់ៗ របស់កសិករ។បញ្ហាផ្នែកកសិកម្មរបស់កសិករត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

# ការត្រួតពិនិត្យជម្ងឺប៉េស្តជ្រូក


**១. សេចក្តីអធិប្បាយ** ........................................ ១

**២. ការណែនាំបច្ចេកទេស** ........................................ ២

**២.១. សង្ខេបនៃការណែនាំបច្ចេកទេស** ........................................ ២

**២.២. ការកំណត់សំគាល់លើការណែនាំបច្ចេកទេស** ........................................ ២

*២.២.១ ចាត់វិធានការណ៍ចាក់វ៉ាក់សាំងជម្ងឺប៉េស្តជ្រូកអោយបានទៀងទាត់* ........................................ ២

*២.២.២ ទិញកូនជ្រូកមានសុខភាពល្អដើម្បីចិញ្ចឹម* ........................................ ៤

*២.២.៣ ត្រូវប្រយត្ន័កុំឱ្យជ្រូកឈឺរស់នៅជាមួយជ្រូកដែលមានសុខភាពល្អ* ........................................ ៥

**២.៣. ផលចំណេញផ្នែកសេដ្ឋកិច្ច** ........................................ ៥

**៣. ការណែនាំលើការងារផ្សព្វផ្សាយ** ........................................ ៦

**៣.១. ការរៀបចំស្ថាប័ន** ........................................ ៦

**៣.២. ការធ្វើផែនការសកម្មភាព** ........................................ ៦

**៣.៣. ឧបករណ៍ និងសំភារះ** ........................................ ៩

**៣.៤. ថវិកាសម្រាប់ការធ្វើបង្ហាញ** ........................................ ១០

**៣.៥. ទីកន្លែងអនុវត្តន៍គំរោង** ........................................ ១២

**៤. ឧបសម្ពន្ធ័** ........................................ ១២

៤.១ ឧបសម្ពន្ធ័ទី១. សៀវភៅសម្រាប់អ្នកគ្រប់គ្រងស្រុក ........................................ ១២

៤.២ ឧបសម្ពន្ធ័ទី២. កំណត់ត្រាសម្រាប់ភ្នាក់ងារសុខភាពពេទ្យសត្វភូមិ ........................................ ១៥

៤.៣ ឧបសម្ពន្ធ័ទី៣. ខិត្តបណ្ណ័សម្រាប់ផ្សព្វផ្សាយពីជម្ងឺប៉េស្ត ........................................ ១៧

៤.៤ ឧបសម្ពន្ធ័ទី៤. ផ្ទាំងរូបភាពសម្រាប់ផ្សព្វផ្សាយពីជម្ងឺប៉េស្ត ........................................ ១៨

៤.៥ ឧបសម្ពន្ធ័ទី៥. បណ្ណ័ព័ត៌មានខ្លីៗសម្រាប់ផ្សព្វផ្សាយពីជម្ងឺប៉េស្ត ........................................ ១៩

៤.៦ ឧបសម្ពន្ធ័ទី៦. បណ្ណ័តំណាងសាច់ប្រាក់សម្រាប់ចាក់វ៉ាក់សាំងជម្ងឺប៉េស្ត ........................................ ២០

## ១. សេចក្តីអធិប្បាយ

**ឈ្មោះអត្ថបទ:** ការត្រួតពិនិត្យជម្ងឺប៉េស្តជ្រូក

**កាលបរិច្ឆេទ:** ខែ មករា ឆ្នាំ ២០០៦

**ប្រភពបទដ្ឋានអនុវត្តបច្ចេកវិទ្យា:** លោក Murray Maclean

**គោលបំណង និង អត្ថប្រយោជន៍:**

- បង្កើនចំណេះដឹង និង ការយល់ដឹងរបស់កសិករពីជម្ងឺប៉េស្តជ្រូក ។
- ធ្វើឱ្យប្រសើរឡើងកំរិតជីវភាពរបស់កសិករតាមរយៈការកាត់បន្ថយអត្រាងាប់ របស់ជ្រូក ដែលបង្កឡើងដោយជម្ងឺប៉េស្តជ្រូក ។
- វានឹងធ្វើឱ្យប្រសើរឡើង នូវទំនាក់ទំនងរវាងអ្នកបច្ចេកទេស និងអ្នកជំនាញខាងផ្សព្វផ្សាយ និងបណ្តាអ្នកពាក់ព័ន្ធដទៃទៀត មានភ្នាក់ងារសុខភាពសត្វភូមិ អ្នក ផ្សព្វផ្សាយ និងមន្ត្រីបច្ចេកទេស ។

**លក្ខខណ្ឌសមស្របទៅតាមបច្ចេកទេស:** ទីកន្លែងចិញ្ចឹមជ្រូកដែលធ្លាប់មានប្រវត្តិផ្ទុះជម្ងឺប៉េស្តជ្រូក ហើយមិនបានធ្វើកម្មវិធី វិធានការត្រួតពិនិត្យចាក់ថ្នាំបង្ការ ។

**ការចូលទិន្នន័យសំខាន់ៗ**

- ភ្នាក់ងារសុខភាពសត្វភូមិជាអ្នកផ្តល់សេវាកម្មសុខភាពសត្វដ៏ប្រសើរមួយ ។ ពួកគេធ្វើការបានជោគជ័យលុះត្រាតែកសិករនៅក្នុងភូមិនោះស្គាល់ និងមានទំនុកចិត្តលើពួកគេក្នុងការព្យាបាលសត្វ ។ ការិយាល័យផលិតកម្ម និងបសុព្យាបាល និងអង្គការក្រៅរដ្ឋាភិបាលជាប្រភពមួយអាចជួយផ្តល់ព័ត៌មាននៅតាមភូមិ ដើម្បី ឱ្យដឹងថានៅក្នុងភូមិមានភ្នាក់ងារសុខភាពសត្វភូមិធ្វើការមានប្រសិទ្ធភាពដែរឬអត់ ។ ការចុះទៅតាមភូមិដើម្បីសំណេះសំណាលជាមួយកសិករ និងភ្នាក់ងារ សុខភាពសត្វភូមិ គឺជាវិធីមួយដ៏ល្អដើម្បីជំរុញអោយភ្នាក់ងារសុខភាពសត្វភូមិ ធ្វើការមានប្រសិទ្ធិភាព ។
- ប្រសិទ្ធិភាពការងាររបស់បុគ្គលិកពេទ្យសត្វស្រុក
- វ៉ាក់សាំងជម្ងឺប៉េស្តជ្រូក

**“បទដ្ឋានអនុវត្តបច្ចេកវិទ្យា ”នេះ** គឺបង្កើតឡើងសម្រាប់ផ្តល់ជូនដល់អ្នកចិញ្ចឹមជ្រូក ទាំងអស់ដែលជួយអោយស្ថានភាពសេដ្ឋកិច្ចគ្រួសារពួកគេផ្លាស់ប្តូរពីក្រទៅមានបាន កសិករគ្រាន់តែចំណាយ១០០០រៀល ដើម្បីចាក់វ៉ាក់សាំងជម្ងឺប៉េស្តជ្រូក ។

## ២. ការណែនាំបច្ចេកទេស

### ២.១- សង្ខេបនៃការណែនាំបច្ចេកទេស

ក-ចាត់វិធានការណ៍ចាក់វ៉ាក់សាំងជម្ងឺប៉េស្តជ្រូកអោយបានទៀងទាត់

ខ-ទិញកូនជ្រូកដែលមានសុខភាពល្អយកមកចិញ្ចឹម

គ- ត្រូវប្រយត្ន័កុំឱ្យជ្រូកឈឺរស់នៅជាមួយជ្រូកដែលមានសុខភាពល្អ

### ២.២- ការកំណត់សំគាល់លើការណែនាំបច្ចេកទេស

#### ២.២.១ ចាត់វិធានការណ៍ចាក់វ៉ាក់សាំងជម្ងឺប៉េស្តជ្រូកអោយបានទៀងទាត់

*ជម្ងឺប៉េស្តជ្រូកនៅក្នុងប្រព័ន្ធកសិកម្មបុរាណនៅកម្ពុជា*

ជម្ងឺប៉េស្តជ្រូក គឺជាជម្ងឺបង្កឡើងដោយវីរុស។ ជម្ងឺនេះបានរាតត្បាតនៅកម្ពុជា ហើយបានចាត់ទុកជាជម្ងឺសំខាន់មួយដែល បានបណ្តាលឱ្យសត្វជ្រូកមានអត្រាងាប់ខ្ពស់។ ជាទូទៅជម្ងឺនេះច្រើនកើតឡើងក្នុងទម្រង់ផ្ទុះឡើងធ្វើឱ្យសត្វជ្រូកងាប់យ៉ាងច្រើន។ វីរុស នេះត្រូវបានរកឃើញនៅក្នុងឈាម លាមក និង សារធាតុរាវដែលចេញពីភ្នែករបស់សត្វជ្រូកឈឺ។ វីរុសអាចរស់នៅក្នុង បរិយាកាសធម្មតា បានពី ២ទៅ៣ថ្ងៃប៉ុណ្ណោះ ហើយវាងាយងាប់ដោយសារដុតកំដៅ កំដៅព្រះអាទិត្យ និង ទឹកថ្នាំសំលាប់មេរោគ។ វីរុសចូលក្នុងសរីរាង្គជ្រូកធ្វើឱ្យសត្វជ្រូកឈឺ សត្វជ្រូកខ្លះមានវីរុសនេះនៅក្នុងខ្លួនតែវាមិនបញ្ចេញរោគសញ្ញាទេ។ ជាធម្មតាវីរុសចូលទៅក្នុងខ្លួនសត្វតាមរយៈ ផ្លូវដកដង្ហើម និងតាមមាត់រួចធ្វើដំណើរទៅក្នុងឈាម និងជាពិសេសបន្ត ទៅតាមសរសៃឈាមផ្សេងៗ របស់សាពាង្គកាយដូចជាស្បែក ក្រពេញទឹករងៃ និងតំរងនោម។ នៅពេលដែលជ្រូកលេចចេញរោគសញ្ញា វីរុសបានទៅនៅក្នុងទឹកនោម លាមក និងសារធាតុរាវនៅក្នុងទឹកភ្នែក ដែលជាឱកាសមួយរបស់វីរុសឆ្លងទៅសត្វជ្រូកដទៃទៀត។

ជ្រូកដែលឈឺអាចចេញរោគសញ្ញាផ្សេងៗគ្នា: ជ្រូកតូចៗខ្លះងាប់ដោយបញ្ចេញរោគសញ្ញាតិចតួច

- សត្វជ្រូកខ្លះទៀតចេញជារោគសញ្ញាដូចជា កំដៅឡើងខ្ពស់ ទន់ល្វេតល្វន់ ទល់លាមក និងស៊ីចំណីតិច



**កូនជ្រូកឈឺជម្ងឺប៉េស្ត កំដៅឡើងខ្ពស់ ដើរល្វេតល្វន់ រាគ និងចូលចិត្តអង្គុយផ្តុំគ្នារបៀបចង្កោងខ្នង**

- សត្វជ្រូកខ្លះបានទៅផ្តុំគ្នានៅកន្លែងតែមួយ ជួនកាលអង្គុយចង្កោងខ្នង
- បន្ទាប់មកស្បែកក្រោមពោះមានលេចពណ៌ក្រហម ក្អក ហៀរទឹកភ្នែក និងដើរល្វេតល្វន់ ។
- ភាគច្រើនជ្រូកបានងាប់រយៈពេល ២-៣ថ្ងៃ ឬជ្រូកខ្លះងាប់រយៈពេល៣សប្តាហ៍បន្ទាប់ពីចេញរោគសញ្ញា ។
- សត្វជ្រូកខ្លះអាចងាប់រហូតដល់ ១-៣ខែ បន្ទាប់ពីចេញរោគសញ្ញា ។

គ្មានថ្នាំព្យាបាលជម្ងឺប៉េស្តជ្រូកទេ ភាគច្រើននៃជ្រូកជិទង់កើតជម្ងឺនេះគេចមិនផុតពីងាប់ឡើយ ។ ចំពោះមេជ្រូកផើមបើកើត ជម្ងឺនេះត្រូវរលូតកូន និងងាប់កូននៅក្នុងពោះ ។

ដើម្បីការពារជម្ងឺប៉េស្ត ជ្រូកត្រូវចាក់ថ្នាំបង្ការ ។ នៅពេលមានផ្ទុះជម្ងឺ ជ្រូកងាប់ត្រូវយកទៅកប់ចោលដើម្បីកាត់បន្ថយនៃការ ចំលងរបស់ជម្ងឺនេះ ចំពោះជ្រូកដែលមានសុខភាពល្អត្រូវបំបែកចេញពីជ្រូកឈឺ ។

នៅកម្ពុជាវ៉ាក់សាំងប៉េស្តជ្រូក ត្រូវបានចែកចាយលក់ដោយផ្នែកឯកជននៅតាមទីផ្សារខេត្ត និងស្រុក ។ វ៉ាក់សាំងនេះត្រូវ រក្សារទុកកន្លែងត្រជាក់ក្នុងកំឡុងពេលស្តុកទុកលក់ និងយកទៅប្រើប្រាស់សម្រាប់ចាក់ជ្រូក ។







**ថ្នាំបង្ការផលិតនៅវៀតណាម ដោយក្រុមហ៊ុន Navetco មានលក់តាមខេត្ត និងស្រុកនៅប្រទេសកម្ពុជា**

### ពេលជម្ងឺផ្ទុះ កសិករ

- ជាធម្មតាកសិករប្រើប្រាស់ឱសថបុរាណដើម្បីព្យាបាល នៅពេលជ្រូកមិនជា ទើបគាត់ហៅភ្នាក់ងារសុខភាពសត្វភូមិ ឬពេទ្យសត្វជំនាញដទៃទៀតដើម្បីជួយព្យាបាលសត្វគាត់ ។
- គាត់មិនប៉ានហៅពេទ្យសត្វជំនាញទេ ពីព្រោះគាត់ខ្លាចពេលសត្វគាត់ងាប់ទៅគាត់មិនអាចយកទៅលក់បាន ។

### ជាធម្មតា កសិករ

- ដឹងពីរោគសញ្ញានៃជម្ងឺប៉េស្តជ្រូកនេះ ពីព្រោះរោគសញ្ញាបែបនេះគាត់បានឃើញកើតលើជ្រូករាល់លើក
- គាត់មិនបានយល់ច្បាស់អំពីជម្ងឺនេះ និងវិធានការការពាររបស់វា ។
- គាត់មិនចូលចិត្តចំណាយលុយទិញថ្នាំបង្ការចាក់ជ្រូក ពីព្រោះគាត់ថាមិនបានទទួលផលប្រយោជន៍អ្វី ។

➢ គាត់សង្ឃឹមថារដ្ឋាភិបាល ឬគំរោង នឹងជួយចេញថ្លៃចាក់វ៉ាក់សាំង និងបំរើសេវាកម្មល្អក្នុងការបង្កើនការយល់ដឹងរបស់កសិករពីជម្ងឺនេះ ។

**ការណែនាំអំពីការចាក់វ៉ាក់សាំង**

មេជ្រូកត្រូវចាក់ថ្នាំបង្ការយ៉ាងហោចណាស់១សប្តាហ៍មុនពេលដាក់បា ។ ចំពោះកូនជ្រូកត្រូវចាក់ថ្នាំបង្ការនៅអាយុ ៦សប្តាហ៍ ។ របៀបប្រើប្រាស់ថ្នាំបង្ការមានបង្ហាញនៅក្នុងក្រដាស ឬ ប្លាកែតជាប់និងដប ជាទូទៅចំណុះថ្នាំបង្ការនៅក្នុងដប មាន ១០ ប ឬ ២៥ កំរិត អាស្រ័យទៅនឹងក្រុមហ៊ុន ។

**ការចាក់វ៉ាក់សាំងត្រូវតែអនុវត្តន៍ដោយភ្នាក់ងារសុខភាពសត្វភូមិ ពីព្រោះ**

- វ៉ាក់សាំងត្រូវរក្សារទុកដាក់នៅកន្លែងត្រជាក់
- វ៉ាក់សាំងដែលយកទៅចាក់ត្រូវប្រើឱ្យអស់ក្នុងពេលតែមួយ
- វ៉ាក់សាំងត្រូវប្រើជាមួយស៊ីរ៉ាំង ឬម្ជុលដែលគ្មានមេរោគ

ជាលទ្ធផល ជាធម្មតាថ្នាំបង្ការមិនអាចផ្តល់ឱ្យគ្រប់អ្នកចិញ្ចឹមជ្រូកនោះទេ តែបើមានកម្មវិធីការចាក់ថ្នាំបង្ការបន្តដូចមុននៅក្នុងភូមិត្រូវតែចាក់ថ្នាំបង្ការឱ្យបានគ្រប់ជ្រូកដើម្បីជៀសវាងកុំឱ្យមានការផ្ទុះទ្រង់ទ្រាយធំនៃជម្ងឺប៉េស្ត ។

### ២.២.២ ទិញកូនជ្រូកមានសុខភាពល្អដើម្បីចិញ្ចឹម

កសិករដែលចង់ទិញកូនជ្រូកចិញ្ចឹម គួរតែទិញកូនជ្រូកពីកសិករចិញ្ចឹមជ្រូក ដែលជ្រូករបស់គាត់មានសុខភាពល្អ ឬម្ចាស់ចិញ្ចឹមជ្រូកដែលបានវ៉ាក់សាំងជម្ងឺប៉េស្តលើមេជ្រូក ។ ការទិញកូនជ្រូកពីកសិករ ឬអ្នកចិញ្ចឹមនៅក្នុងភូមិ វាល្អជាងការទិញកូនជ្រូកពី ឈ្មួញដឹកលក់តាមម៉ូតូ ឬកង់ ។



**កូនជ្រូកទិញពីឈ្មួញដឹកលក់តាមម៉ូតូ ងាយនឹងទទួលជម្ងឺប៉េស្ត**



**កូនជ្រូកលែងស៊ីសេរីនៅក្នុងភូមិ ក៏ជាអ្នកចំលងជម្ងឺដែរ ។**

កូនជ្រូកដែលដឹកលក់តាមម៉ូតូ មិនសូវល្អទេដោយសារកូនជ្រូកទាំងនោះបានប៉ះទង្គិចគ្នានៅពេលដឹកដែលធ្វើឱ្យកូនជ្រូកមាន បញ្ហាស្ត្រេស និងងាយឆ្លងជម្ងឺប៉េស្ត ។ ដូច្នេះកសិករគួរតែទិញកូនជ្រូកពីកសិករគ្នាឯង ឬអ្នកចិញ្ចឹមនៅក្នុងតំបន់របស់ខ្លួន ។

### ២.២.៣ ត្រូវប្រយ័ត្នកុំឱ្យជ្រូកឈឺរស់នៅជាមួយជ្រូកដែលមានសុខភាពល្អ

កសិករត្រូវចិញ្ចឹមជ្រូកក្នុងទ្រុង នេះជាវិធីមួយមិនឱ្យជ្រូកចូលប៉ះពាល់គ្នា ។ បើសិនមានជ្រូកឈឺនៅក្នុងភូមិ

- កសិករត្រូវប្រាកដថាជ្រូកដែលឈឺមិនត្រូវលែងដើរឱ្យស៊ីសេរីពាសវាលពាសកាលនៅក្នុងភូមិទេ ។

- កសិករមិនត្រូវលែងជ្រូកមានសុខភាពល្អឱ្យដើរស៊ីសេរីនៅជុំវិញភូមិទេ ។

- ត្រូវហៅភ្នាក់ងារពេទ្យសតភូមិនៅពេលជ្រូកឈឺ

### ២.៣- ផលចំណេញផ្នែកសេដ្ឋកិច្ច

លទ្ធផលដែលអាចទទួលបានពីការចិញ្ចឹមសត្វអាស្រ័យទៅលើការសំរេចចិត្តរបស់កសិករបានចាក់វ៉ាក់សាំង ឬអត់ ។ វារួមមាន:

- ជ្រូកអាចឆ្លងជម្ងឺឬមិនឆ្លងជម្ងឺ

- ជ្រូកអាចឈឺនៅគ្រប់អាយុ ។ ជ្រូកឈឺ គឺទាក់ទងទៅនឹងកត្តាការផ្តល់ចំណីជាដូចជា (ចំណីតាមបុរាណ និងចំណីផ្សំ) ។ការប្រៀបធៀបលើការវិភាគសេដ្ឋកិច្ចមួយនៃលទ្ធផលនៃការចិញ្ចឹមជ្រូកដោយចាក់វ៉ាក់សាំង ។ ឧទាហរណ៍: កសិករ ម្នាក់បានទិញកូនជ្រូក១ក្បាលទំងន់៧គីឡូក្រាមមកចិញ្ចឹម ដោយឱ្យស៊ីចំណីបុរាណ ដូចជា កន្ទក់ អង្ករបុក និងត្រកួន ។ ក្នុងករណីកូន ជ្រូកមិនបានចាក់វ៉ាក់សាំង នោះកូនជ្រូកនឹងឆ្លងជម្ងឺប៉េស្តបន្ទាប់ពីទិញបាន៥០ថ្ងៃ ហើយធ្វើការព្យាបាលបន្ទាប់មកជ្រូកងាប់ ដែល ធ្វើឱ្យម្ចាស់ ខាតបង់ថវិកា និងពេលវេលា ។

តារាងទី១. ការប្រៀបធៀបថវិកាលើការចិញ្ចឹមកូនជ្រូកដោយចាក់វ៉ាក់សាំង និងមិនបានចាក់វ៉ាក់សាំង

| ការប្រៀបធៀបថវិកាលើការចិញ្ចឹមកូនជ្រូកដោយចាក់វ៉ាក់សាំង និងមិនបានចាក់វ៉ាក់សាំង | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ល.រ | កូនជ្រូកចាក់វ៉ាក់សាំង | | | | កូនជ្រូកមិនចាក់វ៉ាក់សាំង | | | |
| | ឯកតា | តម្លៃឯកតា | ចំនួនឯកតា | តម្លៃរៀល | ឯកតា | តម្លៃឯកតា | ចំនួនឯកតា | តម្លៃរៀល |
| តម្លៃអថេរ | | | | | | | | |
| កូនជ្រូក | គ.ក្រ | ១០.០០០ | ៧ | ៧០.០០០ | គ.ក្រ | ១០.០០០ | ៧ | ៧០.០០០ |
| កន្ទក់ | គ.ក្រ | ៦០០ | ២០ | ១១.៨៧១ | គ.ក្រ | ៦០០ | ២០ | ១១.៨៧១ |
| អង្ករបុក | គ.ក្រ | ៨០០ | ៧ | ៥២៧៦ | គ.ក្រ | ៨០០ | ៧ | ៥២៧៦ |
| ត្រកួន | ថ្ងៃ | ១០០ | ៥០ | ៥០០០ | ថ្ងៃ | ១០០ | ៥០ | ៥០០០ |
| វ៉ាក់សាំងជម្ងឺប៉េស្ត | ក្បាល | ១០០០ | ១ | ១០០០ | ក្បាល | ១០០០ | ០ | ០ |
| ថ្នាំព្យាបាល | ក្បាល | ១០.០០០ | ០ | ០ | ក្បាល | ១០.០០០ | ១ | ១០០០០ |
| | | | | ៩៣,១៤៧ | | | | ១០២១៤៧ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណូល | | | | | | | | |
| តម្លៃកូនជ្រូក | គ.ក្រ | ៧០០០ | ១៥ | ១០២.២៨៥ | គ.ក្រ | ០ | ១៥ | ០ |
| ប្រាក់ចំណេញ = ចំណូល - ចំណាយ | | | | ៩១៣៧ | | | | -១០២១៤៧ |

## ៣. ការណែនាំលើការងារផ្សព្វផ្សាយ

ការណែនាំក្នុងការផ្សព្វផ្សាយ រៀបរាប់អំពីកម្មវិធីផ្សព្វផ្សាយកំរិតឃុំ ។ បន្ទាប់មកនឹងពង្រីកកាន់តែធំនៅតាមតំបន់ថ្នាក់ស្រុក និង ខេត្ត ។

### ៣.១- ការរៀបចំស្ថាប័ន

អ្នកដែលចូលរួមក្នុងកម្មវិធីនេះមាន:

ក- បុគ្គលិកការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត ។ សមាជិកបុគ្គលិកម្នាក់ក្នុងខេត្តត្រូវបានជ្រើសរើសជាអ្នកទទួល ខុសត្រូវផ្នែកសម្របសម្រួលសម្រាប់កម្មវិធីផ្សព្វផ្សាយ ។

ខ- បុគ្គលិកពេទ្យសត្វ នៃការិយាល័យកសិកម្មស្រុកដែលជាប់កិច្ចសន្យាជាអ្នកគ្រប់គ្រងសកម្មភាពការងារនៅក្នុងស្រុក ។ ចំណែកប្រធានការិយាល័យកសិកម្មស្រុក មានតួនាទីក្នុងការពារការគាំទ្រក្នុងកម្មវិធីនេះ ។

គ- ភ្នាក់ងារសុខភាពសត្វភូមិ បើសិនពួកគេចង់បង្កើតជាក្រុមសមាគមន៍ នោះការរៀបចំសមាគមន៍របស់ពួកគេនឹងត្រូវបានទទួលស្គាល់ឧទាហរណ៍: ប្រធានសមាគមន៍មានតួនាទីសំខាន់ក្នុងការដឹកនាំសមាគមន៍ ។ ភ្នាក់ងារសុខភាពសត្វភូមិ ទិញវ៉ាក់សាំង និង ទុកដាក់ប្រាក់ចំណូល ។

ឃ- អាជ្ញាធរដែនដីឃុំ និងភូមិជួយសកម្មភាពកម្មវិធីនេះ

ង- អ្នកផ្គត់ផ្គង់វ៉ាក់សាំងជាធម្មតាត្រូវចុះតាមខេត្ត ហើយយូរៗម្តងត្រូវចុះតាមស្រុក ។

ច- កសិករចូលរួមផ្តល់ព័ត៌មានបង់ថ្លៃថ្នាំបង្ការ និងផ្តល់លទ្ធផលការងារដល់កម្មវិធីវិញ ដើម្បីឱ្យកម្មវិធីនេះដំណើរការ បានប្រសិទ្ធិភាព ។

### ៣.២- ការធ្វើផែនការសកម្មភាព

ផែនការការងារ និងអនុវត្តន៍នូវរយៈពេល៥ខែ ក្នុងនោះមានការធ្វើផែនការ ការសំរាយបំភ្លឺ ការអនុវត្តន៍ការត្រួតពិនិត្យ តាមដានឡើងវិញ និងដំណាក់កាលវាយតម្លៃ ។ កាលបរិច្ឆេទ ថ្ងៃ ខែពិតប្រាកដរបស់កម្មវិធីនិងត្រូវបានកំណត់និងធ្វើការអនុវត្តន៍ផ្សេងៗ គ្នាពីឃុំមួយទៅឃុំមួយអាស្រ័យទៅនឹងកន្លែងធ្លាប់ផ្ទុះជម្ងឺប៉េស្តជាញឹកញាប់ និងតំបន់កសិករធ្វើកសិកម្មពេញមួយឆ្នាំ ។ ជម្ងឺប៉េស្តជ្រូក អាចផ្ទុះឡើងគ្រប់ពេល ប៉ុន្តែនៅខែកក្កដា និងខែសីហា គឺជាខែដែលមានការផ្ទុះនៃជម្ងឺប៉េស្តជ្រូកមានកំរិតខ្ពស់ ។ ខាងក្រោមនេះគឺជា ឧទាហរណ៍ផែនការសកម្មភាពមួយកន្លែងដែលកម្មវិធីបានចាប់ផ្តើមអនុវត្តន៍ការចាក់ថ្នាំបង្កានៅក្នុងខែឧសភា បន្ទាប់ ពីបុណ្យចូលឆ្នាំខ្មែររួច ។

តារាងទី២ ផែនការការងារសម្រាប់កម្មវិធីត្រួតពិនិត្យជម្ងឺប៉េស្ត

| ផែនការការងារសម្រាប់កម្មវិធីត្រួតពិនិត្យជម្ងឺប៉េស្ត | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សកម្មភាពការងារ | ខែ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ការជ្រើសរើសទីកន្លែងអនុវត្តន៍ | | | | | | | | | | | | |
| ការប្រជុំនៅឃុំលើកទី១ ទី២ និងទី៣ | | | | | | | | | | | | |
| ការផ្សព្វផ្សាយ | | | | | | | | | | | | |
| ការចាក់វ៉ាក់សាំង | | | | | | | | | | | | |
| ការតាមដាន | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ស្រុក | | | | | | | | | | | | |
| ការត្រួតពិនិត្យថ្នាក់ខេត្ត | | | | | | | | | | | | |

**ការជ្រើសរើសទីកន្លែងអនុវត្តន៍**

គ្រប់ភូមិទាំងអស់ក្នុងឃុំត្រូវជ្រើសរើសជាគោលដៅរបស់កម្មវិធី ដែលជាកន្លែងជម្ងឺប៉េស្តអាចឆ្លងរាលដាលពីភូមិមួយ ទៅភូមិមួយទៀត ។

**ការប្រជុំថ្នាក់ឃុំលើកទីមួយ**

ការប្រជុំនេះ គឺត្រូវបានរៀបចំដោយអ្នកគ្រប់គ្រងថ្នាក់ស្រុក និងចូលរួមពីអាជ្ញាធរដែនដីឃុំ និងភ្នាក់ងារសុខភាពសត្វភូមិ ។ ការប្រជុំនេះមាន:

- សមាសភាពអ្នកបច្ចេកទេស គឺធ្វើការរំលឹកលើបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ សម្រាប់វិធានការណ៍ត្រួតពិនិត្យជម្ងឺ ប៉េស្ត និងស្ថានភាពកើតឡើងថ្មីៗនៃជម្ងឺប៉េស្តជ្រូកនៅតាមខេត្តស្រុកនិងឃុំ ។ ត្រូវត្រួតពិនិត្យឡើងវិញនូវចំនួនគ្រួសារចិញ្ចឹមសត្វ និងចំនួនជ្រូកនៅភូមិនីមួយៗក្នុងឃុំ ។ ការប្រៀបធៀបរវាងសត្វជ្រូកនៅក្នុងឃុំដែលបានចាក់វ៉ាក់សាំង និងជ្រូកនៅឃុំដ៏ទៃទៀត ដែលមិនបានធ្វើការចាក់វ៉ាក់សាំង ។ អ្នកបច្ចេកទេស និងភ្នាក់សុខភាពសត្វភូមិពិភាក្សាគ្នាពីបទពិសោធន៍របស់ខ្លួន រវាងការចាក់វ៉ាក់ សាំង និងការប្រើប្រាស់ ថ្នាំព្យាបាលជម្ងឺប៉េស្តជ្រូក ។
- សមាសភាពហិរញ្ញវត្ថុ ពិភាក្សាផ្នែកថវិកាសម្រាប់កម្មវិធីចាក់ថ្នាំបង្ការជម្ងឺប៉េស្តជ្រូក ។ ការពិភាក្សានេះគឺជាការប៉ាន់ប្រមាណតំរូវការវ៉ាក់សាំងដែលត្រូវចាក់តាមគោលដៅ ការប៉ាន់ប្រមាណប្រាក់ចំណូលដែលរំពឹងទុក និងការបែងចែក ប្រាក់ចំណូល ។
- សមាសភាពនៃរចនាសម្ព័ន្ធចាត់តាំងពន្យល់ពីសកម្មភាពកម្មវិធី ដែលក្នុងនោះមាន ដំណាក់កាលផ្សព្វផ្សាយ ដំណាក់ កាលចាក់វ៉ាក់សាំង និងដំណាក់កាលធ្វើការតាមដានឡើងវិញ ។

**នៅក្នុងសមាសភាពនៃរចនាសម្ព័ន្ធចាត់តាំងមានៈ**

- ភ្នាក់ងារសុខភាពសត្វភូមិត្រូវរៀបចំជាក្រុម ៣-៤នាក់ ដែលត្រូវធ្វើដំណើរចុះទៅភូមិនិមួយៗក្នុងឃុំ ។

នៅក្នុងឃុំ ត្រូវ មានភ្នាក់ងារសុខភាពសត្វភូមិ ១ ឬ ២ក្រុមដោយអាស្រ័យទៅនឹងចំនួន និងទំហំភូមិ ។ នៅពេលបញ្ចប់នៃកិច្ចប្រជុំ អ្នកចូលរួមទាំងអស់ត្រូវយល់ព្រមលើ:

- ❖ បង្កើតក្រុមការងារសម្រាប់ចាក់វ៉ាក់សាំង
- ❖ ធ្វើកាលបរិច្ឆេទសម្រាប់ចាក់ថ្នាំបង្ការ ថ្នាំបង្ការសម្រាប់ចាក់តាមគោលដៅ ចំនួនថ្នាំបង្ការដែលត្រូវទិញ និងការបែកចែកថវិកាចំណូល ។
- ❖ ចំនួនផ្ទាំងរូបភាព ខិត្តបណ្ណ័ពីជម្ងឺប៉េស្ត និងវិធីចាក់វ៉ាក់សាំងដែលត្រូវចែកចាយទៅភូមិនីមួយៗ ។

**ការផ្សព្វផ្សាយ**

ភ្នាក់ងារពេទ្យសត្វភូមិ និងអាជ្ញាធរដែនដីភូមិសហប្រតិបត្តិការគ្នាដើម្បីផ្តល់ព័ត៌មានដល់កសិករ:

- ❖ ធ្វើការកំណត់ថ្ងៃ-ខែ ពេលវេលា ទីកន្លែង និងតម្លៃវ៉ាក់សាំងនៅលើផ្ទាំងរូបភាព រួចចែកទៅតាមភូមិ និងធ្វើការ ប្រកាសតាមរយៈឧឃោសនស័ព្ទ(មេក្រូ) ។
- ❖ ការបង្ហាញបច្ចេកទេសសម្រាប់ទប់ស្កាត់ជម្ងឺប៉េស្តជ្រូក រួចចែកចាយតាមរយៈខិត្តបណ្ណ័
- ❖ ការបង្ហាញបច្ចេកទេស និងរបៀបគ្រប់គ្រងថវិកានៃកម្មវិធីត្រួតពិនិត្យជម្ងឺប៉េស្តតាមរយៈការរៀបចំប្រជុំជាក្រុមមាន ដូចជា អ្នកចិញ្ចឹមជ្រូកតែមួយក្បាល អ្នកចិញ្ចឹមជ្រូកមេ និងអ្នកចិញ្ចឹមជ្រូកច្រើនក្បាល ។
- ❖ វ៉ាក់សាំងប៉េស្តគឺការពារបានតែជម្ងឺប៉េស្តមួយមុខគត់ វាមិនអាចការពារបានគ្រប់ជម្ងឺទាំងអស់ទេ ។
- ❖ បើសិនកសិករចង់ចាក់ថ្នាំបង្ការសត្វជ្រូករបស់គាត់ នោះគាត់ត្រូវបង់ប្រាក់តម្លៃត្រឹមតែ ១000រៀល ប៉ុណ្ណោះ ។ ការចាក់វ៉ាក់សាំងនេះ ត្រូវប្រតិបត្តិដោយភ្នាក់ងារសុខភាពសត្វភូមិដែលប្រចាំនៅក្នុងភូមិដោយពួកគេត្រូវជូនដំណឹង ទៅភ្នាក់ងារសុខភាពសត្វភូមិឱ្យបាន១ ឬ២ថ្ងៃមុន ។

**ការចាក់វ៉ាក់សាំង**

**ភ្នាក់ងារសុខភាពសត្វភូមិចុះទៅជាក្រុមនៅតាមភូមិនីមួយៗដើម្បី**

- ❖ ធ្វើការចាក់វ៉ាក់សាំង
- ❖ ប្រមូលសេវាកម្មថ្លៃឈ្នួលចាក់វ៉ាក់សាំង
- ❖ កត់ត្រារបាយការណ៍ចាក់វ៉ាក់សាំង
- ❖ ពន្យល់កសិករពីផលប្រយោជន៏នៃការចាក់វ៉ាក់សាំង ។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវបញ្ជាក់ប្រាប់កសិករឱ្យបាន ច្បាស់ថា ការចាក់វ៉ាក់សាំងនេះមិនអាចការពារជម្ងឺជ្រូកទាំងអស់ទេ គឺវាការពារបានតែជម្ងឺប៉េស្តជ្រូកតែមួយប៉ុណ្ណោះ ។ ក្នុងករណីក្រុមភ្នាក់ងារសុខភាពសត្វភូមិ មានគំនិតចុះចាក់វ៉ាក់សាំងនៅភូមិដ៏ទៃផ្សេងៗទៀត ពួកគេនឹងទទួលប្រាក់ ចំណូលបន្ថែម ។

**ការប្រជុំថ្នាក់ឃុំលើកទី ២**

ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ប្រជុំគ្នាជាមួយអ្នកគ្រប់គ្រងស្រុក ដើម្បីវាយតម្លៃលទ្ធផលការងារបច្ចេកទេស

និងហិរញ្ញវត្ថុរបស់កម្មវិធីចាក់វ៉ាក់សាំង និងព្រមទាំងការឆ្លើយតប និងការយល់ដឹងរបស់កសិករ។ ការប្រជុំនេះគឺជាការប្រៀបធៀបរវាងការងាររបស់ក្រុមភ្នាក់ងារសុខភាពសត្វភូមិ និងការផ្តល់យោបល់សម្រាប់ការវិវឌ្ឍន៍ឱ្យកម្មវិធីទៅថ្ងៃ មុខ។

**ការតាមដាន**

ដំណាក់កាលត្រួតពិនិត្យតាមដានកម្មវិធីឡើងវិញ និងបន្តរយៈពេល៣-៤ខែបន្ទាប់ពីការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង។ ក្នុងដំណាក់កាលនេះបុគ្គលិកថ្នាក់ស្រុកចុះទៅ២ដងនៅភូមិនីមួយៗរបស់ឃុំ ដើម្បីធ្វើការប្រជុំជាមួយកសិករ និងភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីពិនិត្យតាមដានឡើងវិញ ពីបទពិសោធន៍កំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំង និងដើម្បីបន្តគាំទ្រយុទ្ធនាការចាក់វ៉ាក់សាំងជម្ងឺប៉េស្ត តទៅទៀតដល់អ្នកចិញ្ចឹមជ្រូកនៅតាមភូមិ និងតាមដានស្ថានភាពជម្ងឺជ្រូកនៅក្នុងភូមិ។

**ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ស្រុក និងខេត្ត**

អ្នកគ្រប់គ្រងថ្នាក់ស្រុក ត្រូវចុះបានទៀងទាត់ក្នុងកំឡុងពេលធ្វើការផ្សព្វផ្សាយ និងដំណាក់កាលប្រតិបត្តិដើម្បីត្រួតពិនិត្យ មើលសកម្មភាពការងាររបស់ភ្នាក់ងារសុខភាពសត្វភូមិ និងតាមដានស្ថានភាពជម្ងឺ។ អ្នកគ្រប់គ្រងថ្នាក់ស្រុកត្រូវធ្វើការប្រជុំឱ្យបាន យ៉ាងហោចណាស់២ដង ជាមួយកសិករដែលបានចូលរួមប្រជុំក្នុងវគ្គផ្សព្វផ្សាយមុន។ ចំពោះអ្នកសំរួលថ្នាក់ខេត្តត្រូវចុះទៅឃុំយ៉ាងហោច ណាស់១ដងក្នុងកំឡុងពេលយុទ្ធនាការចាក់ថ្នាំបង្ការម្តងៗ និងនៅដំណាក់កាលការត្រួតពិនិត្យតាមដានកម្មវិធីឡើងវិញ។

**ការប្រជុំថ្នាក់ឃុំលើកទី៣**

ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ប្រជុំជាមួយអ្នកគ្រប់គ្រងថ្នាក់ស្រុក និងអ្នកសំរបសំរួលថ្នាក់ខេត្ត ដើម្បីធ្វើការវាយតម្លៃលើលទ្ធផលការងារបច្ចេកទេស និងហិរញ្ញវត្ថុរបស់កម្មវិធីចាក់ថ្នាំបង្ការ និងព្រមទាំងការឆ្លើយតប និង ការយល់ដឹងរបស់កសិករ។ ការប្រជុំនេះ គឺជាការប្រៀបធៀបរវាងការងាររបស់ក្រុមភ្នាក់ងារសុខភាពសត្វភូមិ និងផ្តល់យោបល់សម្រាប់ការវិវឌ្ឍន៍កម្មវិធីទៅថ្ងៃមុខ។ សកម្មភាពការងារទៅថ្ងៃមុខគឺបន្តការពិភាក្សាលើវិធានការការត្រួតពិនិត្យជម្ងឺប៉េស្តជ្រូក។ អ្នកគ្រប់គ្រងថ្នាក់ស្រុកសរសេរ របាយកាណ៍ សង្ខេបពីលទ្ធផលកិច្ចប្រជុំ។

**៣.៣- ឧបករណ៍ និងសំភារៈ**

**ខាងក្រោមនេះគឺជាសំភារៈ និងឧបករណ៍សម្រាប់ប្រតិបត្តិការកម្មវិធី**

តារាងទី៣. ឧបករណ៍ និង សំភារៈ

| |
|---|
| សៀវភៅសម្រាប់អ្នកគ្រប់គ្រងថ្នាក់ស្រុក |
| សៀវភៅកត់ត្រាសម្រាប់ភ្នាក់ងារពេទ្យសត្វភូមិ |
| ខិត្តបណ្ណ័ |
| ផ្ទាំងរូបភាព |
| បណ្ណ័តំណាងសាច់ប្រាក់ |
| ឯកសារបច្ចេកទេសសម្រាប់ ភ្នាក់ងារពេទ្យសត្វភូមិ |

សៀវភៅបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ មាននៅការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តដែលជាកន្លែងផ្តល់ព័តិមានលើសុខភាពសត្វ និង គ្រប់គ្រងលើការចេញផ្សព្វផ្សាយព័តិមាន ។

ប្រពន្ធ័ប័ណ្ណតំណាងសាច់ប្រាក់ គឺការងារជំរើសមួយ ដែលបង្ហាញដូចខាងក្រោម:

- បណ្ណ័តំណាងសាច់ប្រាក់សម្រាប់ភូមិមួយ ត្រូវចែកចាយទៅកសិករណាបំពេញតាមលក្ខខណ្ឌ័ត្រឹមត្រូវ (ឧទាហរណ៍ កសិករ ក្រីក្រដែលចិញ្ចឹមជ្រូក១ក្បាល) តាមរយៈប្រធានភូមិកំឡុងពេលធ្វើការផ្សព្វផ្សាយ ។ បណ្ណ័តំណាងសាច់ប្រាក់នេះ មានតម្លៃ១០០០រៀល (ឧទាហរណ៍ តម្លៃចាក់វ៉ាក់សាំងមួយដង) ហើយតម្លៃទឹកប្រាក់ត្រូវបានកំណត់ដាក់លើបណ្ណ័សាច់ប្រាក់ ។ ប្រធានភូមិរក្សាទុកបណ្ណ័ តំណាងសាច់ប្រាក់ និងចែកចាយទៅភ្នាក់ងារពេទ្យសត្វភូមិ ។
- កសិករទុកបណ្ណ័តំណាងសាច់ប្រាក់នេះរហូតដល់ថ្ងៃចាក់វ៉ាក់សាំង
- កសិករឱ្យបណ្ណ័តំណាងសាច់ប្រាក់ទៅភ្នាក់ងារពេទ្យសត្វភូមិជំនួសការបង់ថវិការលើការចាក់វ៉ាក់សាំង
- ភ្នាក់ងារពេទ្យសត្វភូមិ បង្ហាញបណ្ណ័តំណាងសាច់ប្រាក់នៅកិច្ចប្រជុំថ្នាក់ឃុំចុងក្រោយ ហើយបង់ទៅតាមបណ្ណ័តំណាងសាច់ប្រាក់ដែលប្រមូលបាន ។

គោលបំណងប្រពន្ធ័បណ្ណ័តំណាងសាច់ប្រាក់ គឺជំរុញឱ្យកម្មវិធីផ្នែកផ្សព្វផ្សាយកាន់តែប្រសើរឡើង និងអនុញ្ញាតិឱ្យប្រើប្រាស់ជាក្រដាស់ថវិកាសម្រាប់អ្នកចិញ្ចឹមជ្រូកដែលបានចូលរួមក្នុងកម្មវិធី ការត្រួតពិនិត្យជម្ងឺប៉េស្ត ។

## ៣.៤- ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតំរូវការជាក់ស្តែងនៃសាម៉ីអង្គភាព ។ តារាងថវិកាខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យា របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម:

តារាងទី៤. ថវិកាសម្រាប់អនុវត្តន៍

| **ថវិកា និង ការសន្មត់** | ចំនួន/តម្លៃ |
|---|---|
| ក្រុមកសិករ(ក) | ១០០០ជ្រូក/ឃុំ |
| ទុនសម្រាប់ទីកន្លែងបង្ហាញការចាក់វ៉ាក់សាំង(ខ) | $១០០ |
| ការបណ្តុះបណ្តាលក្រុមកសិករ(គ)- ឯកសារ និង ការណែនាំពីបច្ចេកវិទ្យា បអប | $២០០ |
| ទិវាស្រែ(ចាក់វ៉ាក់សាំង) - សំភារៈ (ឃ) | $៤០០ |
| មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ង) | $១៧៥ |
| មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ(ច) | $១០០ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេសជំនាញ(ឆ) | $៤០ |
| **សរុប** | **$១០១៥** |

**ការសន្មត់ប្រើប្រាស់មាន**

ក. ក្នុងTIP មួយ មានជ្រូកកសិករចំនួន ១០០០ជ្រូក ក្នុងមួយឃុំ

ខ. កម្មវិធីចាក់វ៉ាក់សាំងជ្រូកថ្នាក់ឃុំ ដោយពឹងផ្អែកលើប្រព័ន្ធ(ខ័ណ្ឌប័ណ្ណ ឬគូប៉ុង ឬ ប័ណ្ណតំណាងសាច់ប្រាក់) ហើយសំភារៈទាំងអស់ត្រូវបានឧបត្ថម្ភ/ ផ្គត់ផ្គង់ ។ទុនសម្រាប់វ៉ាក់សាំងនេះមានរួមបញ្ចូលទាំងការធ្វើផែនការ ២ដំណាក់ និងការប្រជុំដើម្បីត្រួតពិនិត្យតាមដាន ២ដំណាក់កាល ។

គ. សំភារៈសម្រាប់បណ្តុះបណ្តាលកសិករមាន ធុងទឹកកក=4៥0 ខិត្តប័ណ្ណ=4៥0 ផ្ទាំងរូបភាព=4៥0 និង ព័តិមានកម្ម វិធី=4៥0 សរុបទាំងអស់ =4២00។ មន្ត្រីផលិតកម្មនិងបសុព្យាបាលនៃការិយាល័យកសិកម្មស្រុកចូលរួមប្រជុំ៤ដង រួមទាំងការចុះមូលដ្ឋាន។

ឃ. ការចាក់វ៉ាក់សាំងការពារជម្ងឺប៉េស្ត=4៨00(៨00រៀល,ដៀវសេ x ២ដៀវសេ x ១000ក្បាល) កម្មវិធីនេះ នឹងអនុវត្ត អោយចប់ក្នុងរយៈពេល ៥ថ្ងៃប៉ុណ្ណោះ ដោយត្រូវប្រើកំលាំងភ្នាក់ងារពេទ្យសត្វភូមិចំនួន ១0នាក់

ង. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភប្រចាំថ្ងៃសរុបទាំងអស់ ៥0ថ្ងៃ ដោយមានភ្នាក់ងារពេទ្យសត្វភូមិ ចំនួន ១0នាក់ ។

ច. ប្រាក់ឧបត្ថម្ភសម្រាប់ធ្វើដំណើរ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ៥0ថ្ងៃ

ជ. មន្ត្រីឯកទេសជំនាញការិយាល័យកសិកម្មស្រុក អ្នកផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យតាមដានការបណ្តុះបណ្តាល បអប ។

| ថវិកាអនុវត្តន៏គំរោង | | | | |
|---|---|---|---|---|
| ឈ្មោះ | ឯកតា | តម្លៃជាឯកតា | ចំនួន ឯកតា | តម្លៃ |
| សៀវភៅកត់ត្រាសម្រាប់បុគ្គលិកស្រុក | ឯកតា | | | |
| សៀវភៅកត់ត្រាសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ | ឯកតា | | | |
| បុគ្គលិកស្រុកជាប់កិច្ចសន្យាការងារ | ឯកតា | | | |
| សិក្ខាសាលានៅថ្នាក់ឃុំ | | | | |
| អាហារ | មនុស្ស | | | |
| បណ្ណ័ព័តិមានខ្លីៗសម្រាប់បិទជញ្ជាំង | ឯកតា | | | |
| សំភារៈសម្រាប់បណ្តុះបណ្តាល | ឯកតា | | | |
| ឯកសារបច្ចេកទេស | ឯកតា | | | |
| ផ្ទាំងរូបភាព | ឯកតា | | | |
| ខិត្តបណ្ណ័ | ឯកតា | | | |
| បណ្ណ័តំណាងសាច់ប្រាក់ | ឯកតា | | | |
| បដា | ឯកតា | | | |
| ប្រជុំក្រុមកសិករដើម្បីផ្សព្វផ្សាយ និងដំណាក់កាលតាមដាមឡើងវិញ | ឯកតា | | | |
| អាហារ | ឯកតា | | | |

### ៣.៥-ទីកន្លែងអនុវត្តន៍គំរោង

សកម្មភាពការងារនេះ បានអនុវត្តន៍ជោគជ័យនៅខេត្តបាត់ដំបងក្រោមគំរោង ADESS ។

## ៤. ឧបសម្ពន្ធ័

*៤.១ ឧបសម្ពន្ធ័ទី១. សៀវភៅសម្រាប់អ្នកគ្រប់គ្រងស្រុក*

| | | | | | | |
|---|---|---|---|---|---|---|
| កម្មវិធីចាក់វ៉ាក់សាំងជម្ងឺប៉េស្ត | | | | | | |
| សៀវភៅកំណត់ត្រាសម្រាប់អ្នកគ្រប់គ្រងស្រុក<br>កំណត់ត្រាការប្រជុំលើកទី១នៅថ្នាក់ឃុំ<br>ឈ្មោះ និងតួនាទី អ្នកគ្រប់គ្រងស្រុក:<br>ប្រជុំនៅ ថ្ងៃទី ខែ ឆ្នាំ២០០ ឃុំ ស្រុក ខេត្ត | | | | | | |
| បញ្ជីឈ្មោះអ្នកចូលរួម | | | | | | |
| ល.រ | ឈ្មោះ | | | | | តួនាទី |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| វ៉ាក់សាំងចាក់ជាក្រុម និងវ៉ាក់សាំងចាក់តាមគោលដៅ | | | | | | |
| | ភូមិ | ឈ្មោះភ្នាក់ងារពេទ្យសត្វភូមិ | វ៉ាក់សាំងគោលដៅ (ចំនួនជ្រូក) | ចំណូល(រៀល) ពីគោលដៅ | តំរូវការវ៉ាក់សាំង (ដប) | តម្លៃវ៉ាក់សាំង (រៀល) |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

| កម្មវិធីចាក់វ៉ាក់សាំងជម្ងឺប៉េស្ត | | | | | | |
|---|---|---|---|---|---|---|

សៀវភៅកំណត់ត្រាសម្រាប់អ្នកគ្រប់គ្រងស្រុក

កំណត់ត្រាការប្រជុំលើកទី២នៅថ្នាក់ឃុំ

ឈ្មោះ និងតួនាទី អ្នកគ្រប់គ្រងស្រុកៈ

ប្រជុំ ថ្ងៃទី ខែ ឆ្នាំ២០០០ ឃុំ ស្រុក ខេត្ត

បញ្ជីឈ្មោះអ្នកចូលរួម

| ល.រ | ឈ្មោះ | | | | | តួនាទី |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

កំណត់ត្រាចាក់វ៉ាក់សាំងប្រចាំថ្ងៃ

| | ភូមិ | ចំនួនជ្រូកសរុបក្នុងភូមិ | ចំនួនជ្រូកដែលចាក់វ៉ាក់សាំង | កាលបរិច្ឆេទចាក់វ៉ាក់សាំង | ទឹកប្រាក់សរុបបានបង់(រៀល) | ទឹកប្រាក់សរុបជំពាក់(រៀល) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

| កម្មវិធីចាក់វ៉ាក់សាំងជម្ងឺប៉េស្ត |
|---|
| សៀវភៅកំណត់ត្រាសម្រាប់អ្នកគ្រប់គ្រងស្រុក<br>កំណត់ត្រាការប្រជុំលើកទី៣នៅថ្នាក់ឃុំ<br>ឈ្មោះ និងតួនាទី អ្នកគ្រប់គ្រងស្រុក:<br>ប្រជុំ ថ្ងៃ ខែ ឆ្នាំ២០០ ឃុំ ស្រុក ខេត្ត |
| បញ្ជីឈ្មោះអ្នកចូលរួម |

| ល.រ | ឈ្មោះ | | | | | តួនាទី |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

លទ្ធផលនៃការចាក់វ៉ាក់សាំងពីដើមទីនៃកម្មវិធីរហូតដល់បញ្ចប់នៃកម្មវិធី

| | ភូមិ | ចំនួនជ្រូកសរុបក្នុងភូមិ | ចំនួនជ្រូកបានចាក់វ៉ាក់សាំង | កាលបរិច្ឆេទចាក់ថ្នាំបង្ការ | ទឹកប្រាក់សរុបបានបង់(រៀល) | ទឹកប្រាក់សរុបជំពាក់ (រៀល) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍

| |
|---|
| ១.តើកសិករប៉ុន្មានភាគរយបានយល់អំពីជម្ងឺប៉េស្តជ្រូកនេះ?<br>មុនពេលធ្វើការផ្សព្វផ្សាយ?<br>ក្រោយពេលបានធ្វើការផ្សព្វផ្សាយ?<br>២.តើកសិករប៉ុន្មានភាគរយមានបំណងចង់បង់ថ្លៃសម្រាប់ចាក់វ៉ាក់សាំងជម្ងឺប៉េស្ត?<br>មុនពេលធ្វើការផ្សព្វផ្សាយ?<br>ក្រោយពេលបានធ្វើការផ្សព្វផ្សាយ?<br>៣.តើមានជម្ងឺជ្រូកផ្ទុះឡើងទេបន្ទាប់ពីចាក់វ៉ាក់សាំង?<br>សូមផ្តល់ឱ្យបានលំអិតៈ<br>៤.តើមានចំណុចខ្សោយអ្វីខ្លះសម្រាប់កម្មវិធីផ្សព្វផ្សាយ?<br>៥. តើមានចំណុចខ្លាំងអ្វីខ្លះសម្រាប់កម្មវិធីផ្សព្វផ្សាយ?<br>៦.តើធ្វើដូចម្តេចដើម្បីឱ្យកម្មវិធីផ្សព្វផ្សាយកាន់តែប្រសើរឡើងទៀត? |

### *៤.២ ឧបសម្ពន្ធ័ទី២. កំណត់ត្រាសម្រាប់ភ្នាក់ងារសុខភាពពេទ្យសត្វភូមិ*

កម្មវិធីវ៉ាក់សាំងបង្ការជម្ងឺប៉េស្ត

កំណត់ត្រាភ្នាក់ងារសុខភាពពេទ្យសត្វភូមិ

សម្រាប់ខេត្តៈ

ស្រុកៈ

ឃុំៈ

ភូមិៈ

សមាជិកក្រុមភ្នាក់ងារសុខភាពពេទ្យសត្វភូមិ

កាលបរិច្ឆេទ

| ល,រ | ឈ្មោះគ្រួសារ | ចំនួនជ្រូកដែល<br>បានទទួលវ៉ាក់សាំង | ចំនួន<br>(រៀល) | ចំនួនដែលបាន<br>បង់(រៀល) | ចំនួនដែល<br>ជំពាក់(រៀល) |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១១ | | | | | |
| ១២ | | | | | |
| ១៣ | | | | | |
| ១៤ | | | | | |
| ១៥ | | | | | |
| ១៦ | | | | | |
| ១៧ | | | | | |
| ១៨ | | | | | |
| ១៩ | | | | | |
| ២០ | | | | | |
| ២១ | | | | | |
| | សរុប | | | | |

*៤.៣ ឧបសម្ព័ន្ធទី៣. ខិត្តប័ណ្ណសម្រាប់ផ្សព្វផ្សាយពីជម្ងឺប៉េស្ត*

ផ្នែកខាងមុខ

ជម្ងឺប៉េស្តអាចសំលាប់ជ្រូករបស់អ្នកបាន



អ្នកអាចការពារជ្រូករបស់អ្នកកុំអោយឆ្លងជម្ងឺប៉េស្ត អ្នកត្រូវចាក់វ៉ាក់សាំងជ្រូករបស់អ្នក



វ៉ាក់សាំងជម្ងឺប៉េស្តមានតម្លៃត្រឹមតែ១000 រៀល ប៉ុណ្ណោះ ។

ផ្នែកខាងក្រោយ

បើអ្នកទិញជ្រូកចិញ្ចឹមត្រូវតែចាក់វ៉ាក់សាំង មួយ សប្តាហ៍បន្ទាប់ពីទិញ



បើអ្នកមានជ្រូកមេ ត្រូវចាក់វ៉ាក់សាំងមុនពេលដាក់ ឈ្មោលរយៈពេលមួយសប្តាហ៍ ។



# កាលបរិច្ឆេទចាក់វ៉ាក់សាំងជម្ងឺប៉េស្ត





កាលបរិច្ឆេទៈ

ទីកន្លែងៈ

ជ្រូកមួយក្បាលចំណាយត្រឹមតែ ១000រៀល  សម្រាប់ចាក់វ៉ាក់សាំងជម្ងឺប៉េស្ត

សូមរង់ចាំ ក្រុមចាក់វ៉ាក់សាំង នឹងចុះទៅចាក់ដល់ផ្ទះរបស់អ្នក ។

បណ្តុំព័ត៌មានខ្លីៗសម្រាប់ផ្សព្វផ្សាយជម្ងឺប៉េស្ត



*៤.៦ ឧបសម្ព័ន្ធទី៦. បណ្ណ័តំណាងសាច់ប្រាក់សម្រាប់ចាក់វ៉ាក់សាំងជម្ងឺប៉េស្ត*

**ប័ណ្ណតំណាងសាច់ប្រាក់សម្រាប់ចាក់វ៉ាក់សាំងជម្ងឺប៉េស្ត**



**លេខ......................**

**តម្លៃ ១000 រៀល**